+855 (0)17 774 864
www.sasabassac.com
#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia
ស-សបាសាក់ SA SA BASSAC

# រាក់កំផែល

## ដោយ វណ្ឌី រតនា

*រាក់កំផែល* គឺជាស្នាដៃរូបថតចំនួន ៣៣ រូបដែលបានដកស្រង់ចេញពីកំនត់ត្រារូបភាពដែលបានថតនៅចន្លោះឆ្នាំ២០១០ និង ២០១២ ក្នុងអំឡុងពេលដែលសិល្បករបានកំពុងរស់នៅក្នុងទីក្រុងប៉ារីស៍ និងធ្វើដំណើរនៅក្នុងបណ្ដាប្រទេសអឺរ៉ុប។ *រាក់កំផែល* ជាស្នាដៃថ្មីបន្ទាប់ពីស្នាដៃ *រណ្ដៅបេ* របស់សិល្បករ វណ្ឌី រតនា ដែលបានទទួលការគាំទ្រយ៉ាងក្លាំងក្លារួចមក។ ស្នាដៃថ្មីនេះហាក់ដូចជាឃ្លាតឆ្ងាយពីស្នាដៃមុន ប៉ុន្តែមានទំនាក់ទំនងគ្នាមិនអាចកាត់ផ្តាច់បាន។ ការប្រឈមមុខរបស់សិល្បករជាមួយនឹងស្នាមរបួសផ្លូវកាយនិងផ្លូវចិត្តនៃការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកបានបង្កអោយមានការផ្លាស់ប្តូរនៃទស្សនៈជុំវិញទំនាក់ទនងរវាងសំណេរប្រវត្តិសាស្ត្រ និងការបង្កើតរូបភាព។ រូបថតរបស់រតនា បានក្លាយជារឿងប្រឌិត។

ដោយលែងតំណាងអោយតថភាពទៀតហើយ សិល្បករបានបង្កើតភាពសើៗនៃជីវិតនិងកន្លែងសាធារណៈនិងឯកជន នៅក្នុងមជ្ឈដ្ឋានដែលប្លែកខ្លាំងសម្រាប់គាត់។ រូបភាពទាំងនេះត្រូវបានបង្កើតនិងចងក្រងឡើងជាចំបងដោយប្រើសមាសភាព ដែលរបៀបនៃការមើលជាការបំពេញបន្ថែមលើរបៀបនៃការគិត។ *រាក់កំផែល* មានអមមកជាមួយនូវអត្ថបទរបស់សិល្បករ ដែលកត់ត្រាពីការជួបប្រទះរបស់គាត់អំឡុងពេលថតរូបទាំងនេះ ដែលកើតឡើងដដែលៗជាមួយនឹងភាពខ្វាក់សូន្យសុង និងក្តីមរណា តំណាងអោយព្រំដែននៃគំនិត ភាពល្ងង់ខ្លៅ និងសេរីភាព។

***រាក់កំផែល* អត្ថបទដោយ វណ្ឌី រតនា**

...ពាក្យពេចន៍ដែលគាត់និយាយចេញមកសុទ្ធតែខ្វាក់សម្លេងនិយាយចេញមកក៏ខ្វាក់ហើយខ្ញុំក៏ខ្វាក់ដូចម៉ាស៊ីនថតនិងជុំហ្វីលរបស់ខ្ញុំដែររ៉ូបក្រហមឆើតរបស់កញ្ញាសក់សប្បុរទង់ដែងក៏ខ្វាក់ទៅទៀតច្បាស់ហើយនាងពិតជាមើលមិនឃើញពណ៌រ៉ូបរបស់នាងឡើយសម្លេងស្បែកជើងកែងចោទរបស់កញ្ញាអ្នករដ្ឋធានីប៉ារីស៍រងាររបើកមាត់លែងរួចស្បែកជើងនៅស្ងៀមឆ្កឹងហើយសុទ្ធតែខ្វាក់ទាំងអស់តែម្តងខ្ញុំឥតដឹងទាល់តែសោះថាមានស្នាមទឹកនោមនៅក្នុងស្ថានីយ៍ម៉េត្រូម៉ាល់ស្បែរបស៍នៅសង្កាត់ទី១៧មុខងានរណាម្នាក់ដើរជាន់ទឹកនោមនោះហើយមើលទៅឬក៏អ្នកនោះជាន់ទឹកនោមខ្លួនឯងបើអញ្ចឹងគាត់ពិតជាខ្វាក់នៅក្នុងរូងផ្លូវដ៏ងងឹតនាម៉េត្រូក្រុងប៉ារីស៍ជាមិនខានដៃគូរស្នេហាដ៏សុខសប្បាយមួយគូរចូលចិត្តប្រលោមស្នេហ៍និងជុះនោមក្នុងរូងផ្លូវដ៏ងងឹតនាស្ថានីយ៍ម៉េត្រូជាទីដែលបង្ហាញទិដ្ឋភាពពិតប្រាកដនៃជីវិតអ្នកក្រុងប៉ារីស៍ដែលរាល់សេចក្តីស្លាប់មិនមានភក្តីភាពបន្តិចណាទាល់តែសោះទៅលើរូបពួកគេហើយពួកអ្នកក្រុងប៉ារីស៍ទាំងនោះក៏គ្មានភក្តីភាពបន្តិចណាឡើយចំពោះសេចក្តីស្លាប់របស់ខ្លួនគេផ្ទាល់ដែរគេខ្វាក់ទាំងអស់គ្នាខ្ញុំមានអារម្មណ៍ថានៅឯប៊ែរសួងសុងអាកាសធាតុត្រជាក់ខ្លាំងណាស់ដើមឈើទន្លេបឹងបួរផ្ទះសំបែងឈរភ័យរងារឥតកម្មាហើយព្រមទាំងខ្វាក់មើលមិនឃើញទាំងអស់គ្នាទៀតទាំងសត្វស្លាបស៊ីហ្គញក៏នៅនឹងថ្កល់ហើយខ្វាក់ទាំងអស់តែពួកវាអាចហោះហើរដូចសត្វព្រាបដែរនៅក្នុងទីខ្វាក់ល្ងឹតសូន្យសុងទៅតាមខ្សែរលកវាយោនៃទឹកដីនៃប្រទេសបារាំងហើយខ្សែវាយោដ៏វែងអន្លាយសុទ្ធតែខ្វាក់ល្ងឹតល្ងល់ទៅទៀតវាយោខ្លួនឯងក៏ខ្វាក់ពួកគេទាំងនោះមើលមិនឃើញគ្នាទៅវិញទៅមកទេ...

**អំពីសិល្បករ**

វណ្ឌី រតនា (កើតឆ្នាំ ១៩៨០ នៅភ្នំពេញ) រស់នៅនិងធ្វើការនៅរវាងទីក្រុងភ្នំពេញ ប៉ារីស៍ និងតៃប៉េ។ គាត់ប្រើប្រាស់ម៉ាស៊ីនថតប្រើហ្វីលជាច្រើនប្រភេទ ហើយថតរូបនៅចន្លោះរវាងបែបជាឯកសារនិងសិល្បៈ។ ពិព័រណ៍ជ្រើសរើសមួយចំនួនរបស់គាត់រួមមាន៖ *dOCUMENTA(១៣)*, *ពេលល្អបំផុត ពេលអាក្រក់បំផុត* នៅ Kiev Biennale (២០១២), *នយោបាយដ៏លន្លង់លន្លោច* នៅ Kadist Foundation សហរដ្ឋអាមេរិក (២០១២), *រវាងឋានសួគ៌ និងឋាននរក* នៅសាកលវិទ្យាល័យសារមន្ទីរសិល្បៈសហសម័យ ទីក្រុងមិកស៊ិក (២០១១), *រណ្ដៅបេ* នៅស-សបាសាក់ ភ្នំពេញ (២០១១), ពិព័រណ៍សិល្បៈសហសម័យប្រចាំអាស៊ីប៉ាស៊ីហ្វិករាល់ ៣ ឆ្នាំម្តងលើកទី ៦ (APT6)។

# Surface

## Vandy Rattana

*Surface* is a series of thirty-three photographs selected from a diary of images taken between 2010-2012 while the artist was living in Paris and touring Europe. *Surface* follows Vandy's acclaimed *Bomb Ponds* series, from which it also seemingly departs however is inextricably linked. The artist's confrontation with the physical and psychological scars of the American bombing provoked a shift in philosophy surrounding the relationship between historiography and image making. Photographs, for Vandy, became fiction.

No longer representative of reality, the artist constructed surfaces of public and private life and space in environments alien to him, unified and defined primarily by composition - a way of seeing as an extension of a way of thinking. *Surface* is accompanied by the artist's text, drawn from his encounters photographing, in which repeat encounters with blindness and death symbolize limitations of perception, ignorance and freedom.

***Surface*, select text by Vandy Rattana**

…The words were empty and his voice was blind, me too, I'm blind, like my camera and film. The red robe of the blonde woman is blind. She couldn't see the color of herself, like the other adorable Parisian ladies waiting for trains in dark tunnels. The sounds of their high-heeled shoes became mute, frozen, unmoving, blind. I don't know who pissed in the Paris metro of Malesherbes station at 17e arrondissement. Someone stepped in it, perhaps the same man who pissed, so he must be blind. A blind happy couple seemed to love making love in the dark tunnels. Maybe it was them who pissed there where death is not true to them and they are not true to death because they are both blind. The man is dead. His body is in the museum. He's blind. Perhaps my death would be blind too with no reason, like the death of a longneck bird that pretended to be alive at the same museum, in glass, surrounded by blindness and silence. The silence is blind, me too. In Bersonçon, it was freezing cold, I could feel it, not see it - I'm blind. The trees, the river, the houses were all freezing, blind. Even the cigognes were fixing and they're all blind. They can fly, like pigeons, in a blind space through the wind of France, and the wind is blind. They can't see each other, they feel each other…

**About the Artist**

Vandy Rattana (born 1980, Phnom Penh) lives and works between Phnom Penh, Paris and Taipei. His serial work employs a range of analog cameras and formats, straddling the line between strict documentary and artistic practice. Select exhibitions include: *dOCUMENTA(13)*; *The Best of Times, The Worst of Times,* Kiev Biennale (2012); *Poetic Politic*, Kadist Foundation, USA (2012); *Between Utopias and Dystopias*, Museum University for Contemporary Art, Mexico City (2011); *Bomb Ponds*, SA SA BASSAC, Phnom Penh (2011); 6th Asia Pacific Triennial of Contemporary Art (APT6).

# រាក់កំផែល
## ដោយ វណ្ឌី រតនា

# Surface
## Vandy Rattana

8 December 2012 - 13 January 2013



Vandy Rattana, *France*, 2012, Digital C-Print, 20 x 30 cm, Edition of 4 + AP



Vandy Rattana, *France*, 2012, Digital C-Print, 20 x 30 cm, Edition of 4 + AP